សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ

## ក្រោមប្រធានបទ រាជរដ្ឋាភិបាលខ្មែរត្រូវតែការពារប្រជាពលរដ្ឋរបស់ខ្លួន ។

www.hoksavann.org

ថ្ងៃទី១១ មេសា ២០១២



តាមពត៌មានជាបន្តបន្ទាប់គ្នាថា ពលរដ្ឋខ្មែរដែលទៅធ្វើការនៅបរទេស ជាពិសេសនៅប្រទេសម៉ាឡេស៊ី បានត្រូវគេវាយ ធ្វើការរំលោភសិទ្ធិគ្រប់បែបយ៉ាង ជាពិសេសស្ត្រីខ្មែរដែលបំរើតាមផ្ទះ បានត្រូវម្ចាស់ផ្ទះបង្ខំឲ្យធ្វើការស្ទើរគ្មានពេលសំរាក ជាទាសករដាច់ថ្លៃ រហូតរំលោភផ្លូវភេទទៀតផង ។ ស្ត្រីខ្មែររងគ្រោះខ្លះបានត្រូវអង្គការមនុស្សធម៌រំដោះបានយកត្រឡប់មកប្រទេសកម្ពុជាវិញបានខ្លះ ។ ស្ត្រីខ្មែរខ្លះបានត្រូវបាត់ខ្លួនដោយផុតពេលកំណត់មិនឃើញត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ។ តើនេះជាកំហុសអ្នកណា ? ប្រទេសឥណ្ឌូណេស៊ីបានត្រូវបិទមិនឲ្យស្ត្រីជាតិគេទៅធ្វើការនៅប្រទេសម៉ាឡេស៊ីទៀតឡើយ ដោយប្រទេសនេះបានរំលោភលើស្ត្រីដែលធ្វើការបំរើតាមផ្ទះ ។ រាជរដ្ឋាភិបាលខ្មែរពិតជាបានដឹងរឿងនេះហើយ ហេតុអ្វីបានជាបើកឲ្យក្រុមហ៊ុនជ្រើសរើសកម្មករខ្មែរ ភាគច្រើនជាស្ត្រីទៅធ្វើការនៅប្រទេសនេះ ។ ការមិនយកចិត្តទុកដាក់ប្រជាពលរដ្ឋរបស់ខ្លួនបែបនេះ ហាក់ដូចជារាជរដ្ឋាភិបាលចាត់ទុកប្រជាពលរដ្ឋខ្មែរជាសត្វតិរច្ឆាន ទោះបីត្រូវរងទុក្ខវេទនាបែបណាស្រេចតែយថាកម្មទៅចុះ ។ រហូតមកទល់ពេលនេះ មិនទាន់ឮក្រសួងការបរទេសនៃរាជរដ្ឋាភិបាលខ្មែររួមប្រជុំជាមួយក្រសួងការបរទេសនៃប្រទេសម៉ាឡេស៊ី ដែលជាប្រទេសរំលោភសិទ្ធិកម្មករ ដើម្បីធ្វើសន្ធិសញ្ញាឃោគយល់គ្នាការពារពលរដ្ឋរបស់ខ្លួនឡើយ ឮតែអង្គការក្រៅរដ្ឋាភិបាលប្រឹងប្រែងជួយទៅវិញ ។ ចំណែកក្រុមហ៊ុនដែលជ្រើសរើសកម្មករខ្មែរទៅធ្វើការនៅបរទេស គេគ្មានគិតពីទុក្ខវេទនារបស់កម្មករខ្មែរឡើយ ពួកវាគិតតែរឿងប្រាក់ចំណេញ ដោយយកញើសឈាមស្ត្រីខ្មែរធ្វើជំនួញ ដោយមានម្តាយឪពុកខ្លះបាត់កូនជាយូរឆ្នាំ បានទៅសួរពួកវាមិនឲ្យជួប រហូតឆ្លើយថាមិនដឹង នេះជាអាកប្បកិរិយារបស់ក្រុមហ៊ុនទុច្ចរិតខ្លះ ។ ក្រសួងមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលខ្មែរបានដឹងរឿងនេះ ប៉ុន្តែព្រងើយកន្តើយ មិនយកចិត្តទុកដាក់ចាត់វិធានការតាមផ្លូវច្បាប់ចំពោះក្រុមហ៊ុនទុច្ចរិតនេះសោះឡើយ ។ តើរាជរដ្ឋាភិបាលខ្មែរបានផលប្រយោជន៍ផ្ទាល់ខ្លួនអ្វីខ្លះពីក្រុមហ៊ុននេះ បានជាស្ងប់ស្ងៀមមិនចាត់វិធានការអ្វីសោះ ។ មិនចំពោះតែប្រទេសម៉ាឡេស៊ីទេ មានប្រទេសផ្សេងទៀត ដែលយកកម្មករខ្មែរទៅធ្វើការ ក៏មានបញ្ហាស្រដៀងគ្នាដូចជានៅប្រទេសថៃ ក៏មិនឮរាជរដ្ឋាភិបាលខ្មែរធ្វើការឲ្យបានម៉ឺងម៉ាត់ ការពារអាយុជីវិតប្រជាពលរដ្ឋរបស់ខ្លួនឡើយ ដូចជាថៃបានបាញ់សម្លាប់ពលរដ្ឋខ្មែរដែលចូលដីថៃខុសច្បាប់ ក៏រាជរដ្ឋាភិបាលខ្មែរធ្វើការមិនបានជោគជ័យឲ្យថៃឈប់បាញ់សម្លាប់ពលរដ្ឋខ្មែរឲ្យថៃគោរពច្បាប់អន្តរជាតិឡើយ ។ នេះមកពីរាជរដ្ឋាភិបាលខ្វះសមត្ថភាព ឬខ្វះឆន្ទៈតាមមុខងាររបស់ខ្លួន ។ ប្រជាពលរដ្ឋខ្មែរតាំងពីដើមមក មិនដែលរត់ចោលស្រុកទេ ប៉ុន្តែបើមានរត់ចោលស្រុក ដោយសារតែប្រទេសរបស់ខ្លួនរស់នៅមិនកើតក៏រត់ចោលមួយពេល ដូចជាខ្មែរទៅធ្វើការនៅបរទេសដោយភាពក្រីក្រ គ្មានការងារធ្វើនៅប្រទេសរបស់ខ្លួន ។ ដើម្បីដោះស្រាយរឿងនេះ រាជរដ្ឋាភិបាលត្រូវតែបង្កើតការងារឲ្យប្រជាពលរដ្ឋធ្វើនៅប្រទេសរបស់ខ្លួនឲ្យបានច្រើន ។ ក្រៅពីប្រជាពលរដ្ឋធម្មតា សិស្សនិងនិស្សិតបានរៀនចប់ពីសាលាជាច្រើនម៉ឺននាក់រៀងរាល់ឆ្នាំ ក៏អត់ការងារធ្វើ ។ ចំពោះប្រជាពលរដ្ឋខ្មែរដែលជ្រុលទៅធ្វើការនៅបរទេស ត្រូវក្រុមហ៊ុនក្នុងប្រទេសនិងក្រុមហ៊ុនដែលយកខ្មែរទៅធ្វើការគោរពច្បាប់ឲ្យម៉ឺងម៉ាត់ ។ ចំពោះក្រុមហ៊ុនដែលជ្រើសរើសកម្មករខ្មែរទៅធ្វើការនៅបរទេស បើក្រុមហ៊ុនណាមិនធ្វើតាមច្បាប់ ត្រូវតែបិទក្រុមហ៊ុននោះ បើមានកំហុសធ្ងន់ត្រូវតែប្ដឹងឡើងតុលាការ ដូចជាបង្ខាំងកម្មករខ្មែរដោយខុសច្បាប់ មានខ្លះបានត្រូវស្លាប់ជាដើម ។

ចំពោះប្រជាពលរដ្ឋខ្មែរដែលបាត់ផ្ទះបាត់ដី ដូចជាប្រជាពលរដ្ឋនៅបឹងកក់ នៅបូរីកីឡាជាដើម រងទុក្ខវេទនា ដោយដីសម្បទានរបស់រាជរដ្ឋាភិបាល ក៏ក្រសួងមានសមត្ថកិច្ចរបស់អភិបាលក្រុងភ្នំពេញមិនបានដោះស្រាយប្រកបដោយយុត្តិធម៌គោរពសិទ្ធិប្រជាពលរដ្ឋឡើយ ។ ឃើញតែបង្ក្រាបប្រជាពលរដ្ឋដោយអំពើហិង្សា ចាប់ប្រជាពលរដ្ឋដែលហ៊ានតវ៉ាដាក់ឃុំនិងដាក់ពន្ធនាគារ ដោយតុលាការអយុត្តិធម៌មិនឯករាជ្យ ។ ដើម្បីដោះស្រាយរឿងនេះ រាជរដ្ឋាភិបាលត្រូវតែគោរពសិទ្ធិប្រជាពលរដ្ឋក្នុងការតាំងទីលំនៅ ។ បើប្រជាពលរដ្ឋមានកំហុសខ្លះ ក្រសួងមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលត្រូវប្រើសង្គហធម៌ដោយក្តីសង្រ្គោះ ដើម្បីឲ្យប្រជាពលរដ្ឋមានទីលំនៅ មានទីជីវរស់នៅបានផង ។

ចំពោះបងប្អូនខ្មែរកម្ពុជាក្រោម ដែលមករស់នៅប្រទេសកម្ពុជា ក្នុងមាត្រា៣៣នៃរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នចែងថា «ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ» ។ តើច្បាប់ត្រង់មាត្រានេះ រាជរដ្ឋាភិបាលគិតថាដូចម្តេច ? បើឲ្យសញ្ជាតិដល់បងប្អូនទាំងនោះ តើត្រឹមត្រូវឬទេ ? ការដាក់លក្ខខណ្ឌថា កុំថាកើតនៅកម្ពុជាក្រោម ត្រូវថាកើតនៅប្រទេសកម្ពុជា ទើបឲ្យសញ្ជាតិ ។ លក្ខខណ្ឌនេះបញ្ជាក់ថា រាជរដ្ឋាភិបាលខ្មែរខ្លាចវៀតណាមខ្លាំងពេកទៅ ហ៊ានបំបាត់ដែនដីកម្ពុជាក្រោមដែលជាទឹកដីខ្មែរដែលសភាបារាំងប្រគល់ទៅឲ្យវៀតណាម ។ រាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ននេះត្រូវតែសើរើគំនិតយល់ខុសនេះឡើងវិញ ប្រសើរជាងផ្តល់សញ្ជាតិឲ្យវៀតណាម ដោយគ្រាន់តែគេផ្តល់ឲ្យប្រាក់រាប់រយដុល្លារប៉ុណ្ណោះ ដោយអំពើពុករលួយ ។ សម័យសង្គមរាស្ត្រនិយម រដ្ឋបានផ្តល់សញ្ជាតិឲ្យខ្មែរកម្ពុជាក្រោមដោយស្វ័យប្រវត្តិ ពេលមករស់នៅប្រទេសកម្ពុជា ។៚

*　*

*